*សេចក្តីប្រកាសព័ត៌មាន*

# ប្រធានគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ទស្សនកិច្ចកម្ពុជាដើម្បីតស៊ូមតិ សម្រាប់សុខុមាលភាពកុមារងាយរងគ្រោះបំផុត

**រាជធានីភ្នំពេញ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៣៖** ប្រធានគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ (UNCRC) បានបញ្ចប់ដំណើរទស្សនកិច្ចរយៈពេលពីរថ្ងៃនៅកម្ពុជា ដើម្បីតស៊ូមតិសម្រាប់ការអនុវត្តអនុសាសន៍របស់ខ្លួន ដែលបានធ្វើឡើងកាលពីឆ្នាំ២០២២ ក្នុងគោលបំណងលើកកម្ពស់សុខុមាលភាពកុមារ និងយុវជននៅក្នុងប្រទេសកម្ពុជា។

ក្នុងអំឡុងពេលទស្សនកិច្ច លោកស្រីប្រធានគណៈកម្មាធិការ អាន ស្កេលតុន (Ann Skelton) និងលោកស្រីអនុប្រធាន សូភីអូ ឃីឡាដហ្ស៍ (Sopio Kiladze) បានជួបពិភាក្សាជាមួយមន្ត្រី និងតំណាងមកពីក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យសិទ្ធិកុមារ រួមទាំងបណ្តាញក្មេងជំទង់ និងយុវជន និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាផងដែរ ។

គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ (UNCRC) តាមដានមើលការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ដែលផ្អែកលើគោលការណ៍គន្លឹះនៃសិទ្ធិមានជីវិត សិទ្ធិរស់រាន និងការអភិវឌ្ឍ ការមិនរើសអើង ឧត្តមប្រយោជន៍របស់កុមារ និងសិទ្ធិបញ្ចេញមតិ។ នៅក្នុងឆ្នាំ២០២២ គណៈកម្មាធិការនេះ បានចេញសេចក្តីសង្កេត និងអនុសាសន៍របស់ខ្លួនស្តីពីវឌ្ឍនភាពដែលកម្ពុជាសម្រេចបាន ឆ្ពោះទៅរកការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលជាកាតព្វកិច្ចច្បាប់។

នៅក្នុងកិច្ចពិភាក្សាទាំងនេះ អ្នកជំនាញទាំងពីររូបបានទទួលស្គាល់សមិទ្ធផលដែលសម្រេចបានដោយរាជរដ្ឋាភិបាលកម្ពុជាពីឆ្នាំ២០១១ ដល់ឆ្នាំ២០២៣ ក្នុងកិច្ចការពារ និងបំពេញសិទ្ធិកុមារ ហើយក៏បានលើកឡើងផងដែរពីចំណុចនានាដែលគួរឲ្យព្រួយបារម្ភ។

លោកស្រីប្រធានគណៈកម្មាធិការ អាន ស្កេលតុន បានមានប្រសាសន៍ថា៖ "ជំនួសមុខឲ្យគណៈកម្មាធិកា ខ្ញុំសូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ការទទួលស្វាគមន៍ និងការផ្លាស់ប្តូរយោបល់ប្រកបដោយផ្លែផ្កានៅក្នុងដំណើរទស្សនកិច្ចនេះ។ ប្រទេសកម្ពុជា បានសម្រេចនូវវឌ្ឍនភាពគួរឲ្យកត់សម្គាល់ក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ។ យើងសង្ឃឹមថារាជរដ្ឋាភិបាលនឹងធានានូវការអនុម័តច្បាប់ស្តីពីកិច្ចការពារកុមារ និងការអនុវត្តនូវច្បាប់នេះ។ យើងក៏សូមលើកទឹកចិត្តដល់រាជរដ្ឋាភិបាលក្នុងការបំពេញនូវការប្តេជ្ញាចិត្តរបស់ខ្លួនទាក់ទងនឹងសិទ្ធិកុមារ ដោយអនុម័តនូវពិធីសារបន្ថែមទី៣នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលបង្កើតនូវយន្តការជាតិ ដើម្បីអនុញ្ញាតឲ្យកុមារអាចស្វែងរកនូវសំណងពីការរំលោភបំពានលើសិទ្ធិរបស់ពួកគេ ហើយនៅពេលប្រព័ន្ធច្បាប់របស់ពួកគេមិនអាចផ្តល់នូវដំណោះស្រាយឲ្យបាន។"

អ្នកជំនាញទាំងពីរក៏បានសង្កត់ធ្ងន់លើសារៈសំខាន់នៃការហាមប្រាមនូវការដាក់ទណ្ឌកម្មលើរាងកាយនៅគ្រប់បរិបទទាំងអស់ និងការបន្តប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។

លោកបណ្ឌិត វីល ផាកស៍ នាយកយូនីសេហ្វប្រចាំកម្ពុជា បានមានប្រសាសន៍ថា៖ "តាមរយៈដំណើរទស្សនកិច្ចនេះ សមាជិកទាំងពីរនៃគណៈកម្មាធិការសិទ្ធិកុមារ បានរួមចំណែកចែករំលែកចំណេះដឹង និងទស្សនៈទាក់ទងនឹងសិទ្ធិ ដល់កិច្ចខិតខំប្រឹងប្រែង

របស់រាជរដ្ឋាភិបាល ក្នុងការលើកស្ទួយសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា”។ “អាជ្ញាធរជាតិកំពុងធ្វើការងារត្រឹមត្រូវក្នុងការអនុវត្តតាមអនុសាសន៍ភាគច្រើនបំផុត ដែលបានលើកឡើងដោយគណៈកម្មាធិការសិទ្ធិកុមារកាលពីឆ្នាំ២០២២។ យូនីសេហ្វបន្តប្តេជ្ញាចិត្តគាំទ្ររាជរដ្ឋាភិបាលកម្ពុជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីសម្រេចបានសិទ្ធិកុមារ និងបង្កើតអនាគតមួយដែលកុមារទាំងអស់អាចចម្រើនលូតលាស់ រៀនសូត្រ លេងកំសាន្ត អភិវឌ្ឍ និងរីកចម្រើនប្រកបដោយសេចក្តីថ្លៃថ្នូរនៅក្នុងគ្រួសារ និងបរិស្ថានសហគមន៍របស់ខ្លួន។”

ដោយយកអនុសញ្ញាស្តីពីសិទ្ធិកុមារជាគោល យូនីសេហ្វ គឺជាស្ថាប័នសហប្រជាជាតិ ដែលមានអាណត្តិការពារសិទ្ធិកុមារគ្រប់រូប និងធ្វើការជាមួយដៃគូនានា រួមទាំងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអនុវត្តតាមអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ។

###

**អំពីយូនីសេហ្វ**

យូនីសេហ្វបំពេញការងារនៅតាមតំបន់ ដែលជួបការលំបាកបំផុតមួយចំនួននៅក្នុងពិភពលោក ដើម្បីគាំទ្រដល់កុមារដែលជួបការលំបាកជាងគេនៅក្នុងពិភពលោក។ ជាមួយវត្តមាននៅក្នុងប្រទេស និងដែនដីជាង ១៩០ យើងធ្វើការដើម្បីកុមារគ្រប់រូបនៅគ្រប់ទិសទី ដើម្បីកសាងពិភពលោកកាន់តែប្រសើរសម្រាប់គ្រប់គ្នា។

សម្រាប់ព័ត៌មានបន្ថែមអំពីយូនីសេហ្វ និងការងាររបស់យូនីសេហ្វក្នុងប្រទេសកម្ពុជា សូមចូលមើលវេបសាយ៖ https://www.unicef.org/cambodia

សូមតាមដានព័ត៌មានអំពីយូនីសេហ្វកម្ពុជាតាមរយៈ Facebook | Twitter | YouTube | Instagram | Linkedin | Threads | TikTok

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖**
លោក អាគ្រាន បូណូ ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វកម្ពុជា
ទូរសព្ទ ៖ +៨៥៥ ២៣២៦០២០៤ សារអេឡិចត្រូនិក៖ hbonnaud@unicef.org
លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង យូនីសេហ្វកម្ពុជា
ទូសព្ទ ៖ +៨៥៥ ៩២២៤២៦២ សារអេឡិចត្រូនិក៖ bmeas@unicef.org